# ការចុះអនុស្សរណៈយោគយល់គ្នា

នារសៀលថ្ងៃព្រហស្បតិ៍ ១១ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ឯកឧត្តម ឈុន សម្បត្តិ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. និងឯកឧត្តមបណ្ឌិត ជា វុធណា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពី "កិច្ចសហប្រតិបត្តិការលើការចែករំលែកព័ត៌មាន និងការពង្រឹងសមត្ថភាពមន្ត្រី"។

## ជាមួយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃ កសហវ





ការចុះ MOU នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើតនូវកិច្ចសហប្រតិបត្តិការដើម្បីចែករំលែកចំណេះដឹង ជំនាញ បទពិសោធន៍ការងារ និងព័ត៌មាន។ ពិធីចុះ MOU នាថ្ងៃនេះ មានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ តំណាងដ៏ខ្ពង់ខ្ពស់ពីអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងនិយ័តករក្រោមឱវាទ អ.ស.ហ. ផងដែរ។ ពិធីចុះ (MOU) នេះ បានប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងកិច្ចសហការខ្ពស់ពីភាគីព័ន្ធទាំងអស់។







